## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា ( MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខ: ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខ: ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមបំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ សមាគមមានសមាជិកសរុបចំនួន ៣២៩ស្ថានីយ / ក្រុមហ៊ុន ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកអាជីពចំនួន ២៨៥ស្ថានីយ និងសមាជិកគាំទ្រចំនួន ៤៤ក្រុមហ៊ុន។

# ២. ការងាររដ្ឋបាលសមាគម

## ២.១ ដំណើរទស្សនកិច្ចសិក្សា

នៅក្នុងត្រីមាសទី៣ សមាគមបានដឹកនាំសមាជិកធ្វើទស្សនៈកិច្ចសិក្សា ដើម្បីស្វែងយល់ និងរៀនសូត្របន្ថែមអំពីចង្វាក់ផលិតកម្មនៃការផលិត និងផ្គត់ផ្គង់ទឹកស្អាតចំនួន ៣លើកដូចខាងក្រោម៖

- **លើកទី១៖** ចូលរួមវេទិកាទឹកលើកទី៦ និងពិព័រណ៍ទឹកថៃ នៅទីក្រុងបាងកក ដែលមានអ្នកចូលរួមសរុប ៥៩នាក់ (ស្រី ២៨នាក់) នៅថ្ងៃទី៣-៥ ខែកក្កដា ឆ្នាំ២០២៤។



*រូបភាពទី១៖ ទស្សនកិច្ចសិក្សានៅស្ថានីយផលិតទឹកស្អាត មហាសារ៉ាត់ (ប្រទេសថៃ)*

- **លើកទី២៖** សមាគមបានដឹកនាំគណៈប្រតិភូមកពីប្រទេសម៉ាឡេស៊ី សឹង្ហបុរី សមាជិកសមាគម និងមន្ត្រីនៃក្រសួងសាធារណៈការ និងដឹកជញ្ជូន ទៅទស្សនកិច្ចសិក្សាស្វែងយល់អំពីចង្វាក់ផលិតកម្ម និងការផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរោងចក្រផលិតទឹកស្អាត បាក់ខែង ដែលមានអ្នកចូលរួមសរុប ៤៦នាក់ (ស្រី១១នាក់) នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤ ។






*រូបភាពទី២៖ ទស្សនកិច្ចសិក្សាស្វែងយល់អំពីចង្វាក់ផលិតកម្ម និងការផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរោងចក្រផលិតទឹកស្អាត បាក់ខែង*

❖ **លើកទី៣៖** តបតាមការអញ្ជើញរបស់ក្រុមហ៊ុន ធីស៊ីយូ សមាគម មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្ត(បាត់ដំបង កំពង់ស្ពឺ កំពង់ចាម និងស្ទឹងត្រែង) រដ្ឋាករសាធារណខេត្តស្ទឹងត្រែង និងខេត្តស្វាយរៀង ព្រមទាំងប្រតិបត្តិករឯកជន បានចូលរួមដំណើរទស្សនកិច្ចសិក្សារោងចក្រផលិតសម្ភារៈទឹកស្អាតវៃឆ្លាត WPG (Shanghai) Smart Water Public Co., Ltd នៅទីក្រុងសៀងហៃ សាធារណៈរដ្ឋប្រជាមានិតចិន ពីថ្ងៃទី ២១-២៤ ខែកញ្ញា ឆ្នាំ២០២៤។



*រូបភាពទី៣៖ ទស្សនកិច្ចសិក្សានៅរោងចក្រផលិតសម្ភារៈទឹកស្អាតវៃឆ្លាត*

## ២.២ វគ្គបណ្តុះបណ្តាល

នៅក្នុងត្រីមាសទី៣ សមាគម បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**ការសន្សំសំចៃថាមពល សម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជន**» ចំនួន១លើក ជូនដល់សមាជិក ដែលមានអ្នកចូលរួមសរុបចំនួន ២២នាក់(ស្រី ៤នាក់) ក្នុងនោះមាន ១៥ ស្ថានីយ និង១ក្រុមហ៊ុន។ ក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាលសិក្ខាកាមមានលទ្ធភាព៖

- ❖ កំណត់បានពីប៉ារ៉ាម៉ែត្រសំខាន់ៗ សម្រាប់ជ្រើសរើសម៉ាស៊ីនបូមទឹក
- ❖ កំណត់បានពីការប្រើប្រាស់ប្រព័ន្ធសូឡាសម្រាប់ស្ថានីយ
- ❖ កំណត់បានពីអត្ថប្រយោជន៍នៃការប្រើប្រាស់ថាមពលអគ្គិសនី។



*រូបភាពទី៤៖ សិក្ខាកាមទទួលវិញ្ញាបនបត្រ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល*

## ២.៣ ការវិភាគគុណភាពទឹកជូនសមាជិក

❖ ក្នុងត្រីមាសទី៣ សមាគមបានផ្តល់ជំនួយបច្ចេកទេស តាមរយៈការផ្តល់ការបង្វឹកទៅលើការអនុវត្តការវិភាគគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥ ដល់ស្ថានីយចំនួន៤ រួមមាន៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ម៉ារីន ពេជសារ

២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បុរីជលសារ

៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ជា សារឿន

៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រលាំងចក។



*រូបភាពទី៥៖ បុគ្គលិកសមាគមបង្វឹកផ្ទាល់លើការអនុវត្តការវិភាគគុណភាពទឹកស្អាតលើ ៥ប៉ារ៉ាម៉ែត្រ ប្រចាំថ្ងៃ*

❖ ធ្វើជ្យារតេស្តទឹកនៅជូនសមាជិកបានចំនួន ៥ស្ថានីយ ដើម្បីកំណត់បរិមាណសារធាតុគីមីដែលត្រូវប្រើសម្រាប់ផលិតទឹកស្អាតឱ្យបានត្រឹមត្រូវជូនស្ថានីយ៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រពុំឈូក ខេត្តតាកែវ

២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភូមិយើង ឃុំលើកដែក ខេត្តកណ្តាល

៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កោះអណ្តែត ខេត្តតាកែវ

៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ម៉ារីនពេជសារ ខេត្តតាកែវ

៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទំនប់ជើងព្រៃ ខេត្តកំពង់ចាម។



*រូបភាពទី៦៖ បុគ្គលិកសមាគម បានធ្វើជ្យារតេស្តទឹកនៅជូនសមាជិក*

## ២.៤ ការចុះសួរសុខទុក្ខ និងបង្វឹកដល់សមាជិក

នៅក្នុងត្រីមាសទី៣ សមាគម បានចុះសួរសុខទុក្ខ និងបង្វឹកបន្ថែមលើជំនាញវិភាគគុណភាពទឹកស្អាត និងធ្វើជ្យារតេស្តទឹកផៅ ជូនស្ថានីយចំនួន ៨ស្ថានីយ៖

១. ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត កោះអណ្តែត ខេត្តតាកែវ
២. ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រពុំឈូក ខេត្តតាកែវ
៣. ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត សំរោង ខេត្តព្រៃវែង
៤. ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ជា សារឿន ខេត្តកំពង់ស្ពឺ
៥. ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត វលាំងចក ខេត្តកំពង់ស្ពឺ
៦. ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភូមិយើងឃុំលើកដែក ខេត្តកណ្តាល
៧. ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត វុទ្ធាទឹកស្អាត ខេត្តកំពង់ចាម
៨. ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ នៅក្រុមហ៊ុន L.A.A INVESTMENT CO,. LTD ខេត្តតាកែវ។



*រូបភាពទី៧៖ បុគ្គលិកសមាគមចុះសួរសុខទុក្ខ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស*

## ២.៥ សំណើសុំកិច្ចអន្តរាគមន៍ក្នុងការអនុគ្រោះលើកលែងពន្ធ និងជួយដោះស្រាយបញ្ហារបស់ប្រតិបត្តិករ

នៅក្នុងត្រីមាសទី៣ សមាគមបានរៀបចំលិខិតគោរពជូន **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួង ឧវបន ដើម្បីស្នើសុំកិច្ចអន្តរាគមន៍ក្នុងការអនុគ្រោះលើកលែងពន្ធ និងជួយដោះស្រាយបញ្ហារបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនដែលបាន នឹងកំពុងជួបប្រទះ នៅថ្ងៃទី២០ ខែសីហា ឆ្នំ២០២៤។

## ២.៦ កិច្ចប្រជុំថ្នាក់តំបន់

នៅក្នុងត្រីមាសទី៣ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួន ២លើក ក្នុងគោលបំណង៖

❖ **លើកទី១៖** នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករអញ្ជើញមកពីខេត្តកំពង់ស្ពឺ តាកែវ កែប កំពត ព្រះសីហនុ និងខេត្តកោះកុង។ កិច្ចប្រជុំរៀបចំនៅរមណីយដ្ឋានភូមិសេរីមង្គល ខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាព **លោក នួន សុកណ្ណ** ប្រធានមន្ទីរ ឧវបន ខេត្តកំពង់ស្ពឺ និង **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ១០៣នាក់ (ស្រី ២០នាក់) រួមមាន៖ ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ ឧវបន ខេត្តកំពង់ស្ពឺ អង្គការ Water.org ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម តំណាងក្រុមហ៊ុន តំណាងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភធំពីអង្គការ Water.org និងសហការឧបត្ថម្ភ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK និងក្រុមហ៊ុនរួមមាន៖ ១) ក្រុមហ៊ុន TCU ២) ក្រុមហ៊ុន X-Water ៣) ក្រុមហ៊ុន UPG Pipe ៤) ក្រុមហ៊ុន MK Waterware ៥) ក្រុមហ៊ុន LESSO ៦) ក្រុមហ៊ុន CHIP MONG ៧) ក្រុមហ៊ុន LEO Pump Cambodia និង ៨) ក្រុមហ៊ុន AMO។



*រូបភាពទី៨៖ កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តកំពង់ស្ពឺ*

❖ **លើកទី២៖** នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករអញ្ជើញមកពីខេត្តសម្រាប់ប្រតិបត្តិករអញ្ជើញមកពីភ្នំពេញ ខេត្តកណ្ដាល ព្រៃវែង ស្វាយរៀង និងប្រតិបត្តិករដែលមិនទាន់បានចូលរួមកិច្ចប្រជុំថ្នាក់តំបន់ នាពេលកន្លងមក។ កិច្ចប្រជុំរៀបចំនៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ ក្រោមអធិបតីភាព **លោក ហួត វណ្ណថូ** ប្រធានមន្ទីរ ឧវបន ខេត្តកណ្ដាល និង **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៩៥នាក់(ស្រី ១៦នាក់) រួមមាន៖ ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ ឧវបន ខេត្តកំពង់ស្ពឺ អង្គការ Water.org ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម តំណាងក្រុមហ៊ុន តំណាងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភធំពីអង្គការ Water.org និងសហការឧបត្ថម្ភ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ និងក្រុមហ៊ុនរួមមាន៖ ១) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK ២) ក្រុមហ៊ុន TCU ៣) ក្រុមហ៊ុន X-Water ៤) ក្រុមហ៊ុន LEO Pump ៥) ក្រុមហ៊ុន CHIP MONG Cambodia និង ៦) ធនាគារ FTB។




*រូបភាពទី៩៖ កិច្ចប្រជុំថ្នាក់តំបន់នៅ រាជធានីភ្នំពេញ*

## ៣. កិច្ចសហប្រតិបត្តិការ

ក្នុងត្រីមាសទី៣ សមាគមបានជួបប្រជុំជាមួយអង្គការដៃគូដើម្បីពិភាក្សាអំពីគម្រោង និងសហការរួមមាន៖

- ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ នាយកប្រតិបត្តិសមាគម បានទទួលជួបប្រជុំសម្តែងការគួរសមជាមួយ លោក YAMAMOTO Koji ប្រធានថ្មីរបស់ក្រុមហ៊ុនសេវាទឹកទីក្រុងគីតាយូស៊ូ ជំនួស លោក ARITA Hitoshi ដែលបានចូលនិវត្តន៍ ដើម្បីរឹតចំណងមិត្តភាព សាមគ្គីភាព និងបង្កើនកិច្ចសហការជាមួយគ្នា។



*រូបភាពទី១០៖ កិច្ចប្រជុំសម្តែងការគួរសមជាមួយ លោក YAMAMOTO Koji*

- ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ សមាគម និងសមាជិក បានចូលរួមក្នុង «**វេទិកាទឹកស្អាត**» នៅសណ្ឋាគារសុខា ភ្នំពេញ ដែលរៀបចំឡើងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។




*រូបភាពទី១១៖ សមាគម និងសមាជិកបានចូលរួមក្នុងវេទិកាទឹកស្អាត*

- ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម បានចូលរួមសិក្ខាសាលាស្តីពី**«ការសិក្សាលើកទី២ អំពីប្រព័ន្ធគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ទឹកស្អាត»** នៅសាលប្រជុំនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងគោលបំណងដើម្បីធ្វើការសិក្សាទីផ្សារ ណែនាំពីផលិតផលផ្សព្វផ្សាយ និងពង្រីកឲ្យបានទូលំទូលាយនូវការប្រើប្រាស់ប្រព័ន្ធ។




*រូបភាពទី១២៖ សិក្ខាសាលាស្តីពី «ការសិក្សាលើកទី២ អំពីប្រព័ន្ធគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ទឹកស្អាត»*

- ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ សមាគមបានជួបប្រជុំជាមួយអង្គការ EMW ដើម្បីពិភាក្សាពីការអនុវត្តគម្រោងនាពេលកន្លងមក និងរួមគ្នាបង្កើតគម្រោងថ្មីនាពេលអនាគតដ៏ខ្លីខាងមុខ ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាត និងអនាម័យ តាមរយៈប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី១៣៖ កិច្ចប្រជុំជាមួយអង្គការ EMW*

- ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤ ជួបប្រជុំជាមួយ Mr. Masaya USHIDA, ប្រធានក្រុមហ៊ុន Hitz Hitachi Zosen និងសហការីស្តីពីការរៀបចំសិក្ខាសាលាក្នុងការបង្ហាញផលិតផលប្រព័ន្ធចម្រោះទឹកស្អាតដោយប្រព័ន្ធភ្នាសសរសៃលឿន ( Rapid Fiber Filtration System) ដែលគ្រោងនឹងរៀបចំនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ នៅសណ្ឋាគាររីវើសាយ ខេត្តពោធិ៍សាត់។



*រូបភាពទី១៤៖ កិច្ចប្រជុំជាមួយ Mr. Masaya USHIDA, ប្រធានក្រុមហ៊ុន Hitz Hitachi Zosen និងសហការី*

- រសៀលថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ សមាគមបានទទួលជួបប្រជុំជាមួយ ប្រធាននាយដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង និងសហការី នៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួង ឧរបន នៅការិយាល័យសមាគម ដើម្បីពិភាក្សាអំពីការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងទឹកបាត់បង់ ជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។



*រូបភាពទី១៥៖ កិច្ចប្រជុំជាមួយប្រធាននាយដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង និងសហការី*

## ៤. ការអភិវឌ្ឍសមាគម និងការផ្សព្វផ្សាយ

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ សមាគមមានការផ្សព្វផ្សាយព័ត៌មានតាមរយៈទំព័រហ្វេសប៊ុក ដែលមានលទ្ធផលដូចខាងក្រោម៖

| ល.រ | ការបរិយាយ | កក្កដា-កញ្ញា ឆ្នាំ២០២៤ |
|---|---|---|
| ១ | ផ្សព្វផ្សាយបាន | ៧៥ដង |
| ២ | មានអ្នកបានឃើញ (Reach) | ៣៣,៣៥៨នាក់ |
| ៣ | មានការចែកចាយបន្ត និងការចូលរួម | ៣៥៦ដង |
| ៤ | សរុបចំនួនអ្នកចុចចូលចិត្ត (like page) | ១២,៣០០នាក់ |
| ៥ | សរុបចំនួនអ្នក Follower | ១៣,៨៥៥នាក់ |

## ៥. ការងារគម្រោង

### ៥.១ គម្រោង«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត» គាំទ្រដោយអង្គការ Water.org

#### ៥.១.១ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកបច្ចេកទេស

សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត/មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត ក្នុងការផ្តល់វគ្គបង្វឹកតាមស្ថានីយផ្ទាល់។ កម្មវិធីបង្វឹកនេះមានគោលបំណងឲ្យអ្នកចូលរួមបានសិក្សាស្វែងយល់ និងអនុវត្តអំពីការប្រតិបត្តិការ និងថែទាំប្រព័ន្ធសម្អាតទឹក ការតេស្តគុណភាពទឹក និងការកត់ត្រា ដើម្បីបានជាចំណេះដឹង និងដកស្រង់បទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមក។ នៅចុងបញ្ចប់វគ្គបង្វឹក អ្នកចូលរួមអាចមានលទ្ធភាព៖

១. ពិនិត្យ និងអនុវត្តការធ្វើតេស្តទឹកលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥ តាមរយៈឧបករណ៍តេស្តគុណភាពទឹក

២. កំណត់បានចំណុចដែលត្រូវកែលម្អដល់ស្ថានីយលើផ្នែកបច្ចេកទេស និងពន្យល់បានអនុសាសន៍ដែលត្រូវអនុវត្ត។

នៅក្នុងត្រីមាសទី៣ បុគ្គលិកសមាគមបានចុះសួរសុខទុក្ខ និងផ្តល់វគ្គបង្វឹកដល់សមាជិកចំនួន ១៦ស្ថានីយ ដូចខាងក្រោម៖

| ល.រ | ឈ្មោះស្ថានីយ | ល.រ | ឈ្មោះស្ថានីយ |
|---|---|---|---|
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាតម៉ារីនពេជសារ | ៩ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត គគ្រួស |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្រពាំងធំ ដានាង | ១០ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អង្គតាសោម |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កណ្តឹង | ១១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេង ខៀវ ព្រៃកអំបិល |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សំពោងយ៉ោង | ១២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំស្វាយរមៀត |
| ៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រះស្តេច | ១៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រែកជ្រៃ |
| ៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ល្វារំចេក | ១៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដំរីផុង |
| ៧ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បាភ្នំ | ១៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កន្ទួត |
| ៨ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំជ្រៃ | ១៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្វាយជ្រះ |




*រូបភាពទី១៦៖ ការផ្តល់វគ្គបង្វឹកតាមស្ថានីយផ្ទាល់ នៅស្ថានីយគគ្រួស និងស្ថានីយកណ្តឹង*

តាមរយៈនៃការបង្វឹកលើការវិភាគគុណភាពទឹកឆៅ និងទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥ បច្ចេកទេសក្នុងការប្រើប្រាស់សារធាតុគីមី និងសិក្សាពីប្រភពទឹករហូតដល់ស្ថានីយចែកចាយទឹកស្អាត ព្រមទាំងបានផ្តល់ជាអនុសាសន៍សម្រាប់ម្ចាស់ និងបុគ្គលិកស្ថានីយដើម្បីធ្វើការកែលម្អ។ អនុសាសន៍ទាំងអស់នេះអាចនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រតិបត្តិករដូចជា៖

១. ចំណេញថវិកាពីការចំណាយលើការប្រើប្រាស់សារធាតុគីមីប្រចាំថ្ងៃយកមកផលិតទឹកស្អាត
២. ផលិតទឹកស្អាតមានគុណភាពអនុលោមតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ
៣. រៀបចំស្ថានីយ និងបរិវេណស្ថានីយបានស្អាត មានអនាម័យល្អ ព្រមទាំងមានសុវត្ថិភាព
៤. ធានាក្នុងការផលិត និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋក្នុងតំបន់អាជ្ញាបណ្ណប្រកបដោយសុវត្ថិភាព។

### ៥.១.២ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ

សមាគមបានតាមដានដំណើរការនៃការគាំទ្ររវាងប្រតិបត្តិករចំនួន ៥ស្ថានីយ និងក្រុមហ៊ុន EAST WING AUTIDTING & CONSULTING CO., LTD (EW)។ ជាលទ្ធផល ប្រតិបត្តិករចំនួន ៣ស្ថានីយបានបើកសមតុល្យដើមគ្រាបានចប់សព្វគ្រប់ និងចាប់ផ្តើមកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៣ រួចរាល់។ សម្រាប់ស្ថានីយចំនួន២ ទៀតកំពុងតែប្រមូលព័ត៌មាន និងទិន្នន័យបន្ថែមដើម្បីបើកសមតុល្យដើមគ្រា។

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារសមាគម អង្គការ Water.org បានជួបប្រជុំពិភាក្សាជាមួយក្រុមហ៊ុនបញ្ញី ដើម្បីពិភាក្សាអំពីការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«នីតិវិធីប្រតិបត្តិការហិរញ្ញវត្ថុស្តង់ដាសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន (Standard Financial Operating Procedures for Private Water Operators)»។ ជាលទ្ធផល គម្រោងនឹងរៀបចំវគ្គបណ្តុះបណ្តាលជាពីរវគ្គ ដែលត្រូវការរយៈពេល៥ថ្ងៃ (វគ្គទី១៖ ៣ថ្ងៃ និងវគ្គទី២៖ ២ថ្ងៃ)។ វគ្គបណ្តុះបណ្តាលនេះនឹងប្រព្រឹត្តទៅនៅខែតុលា ឆ្នាំ២០២៤។

### ៥.១.៣ ការគាំទ្រលើការងារស្នូលរបស់សមាគម

នៅក្នុងត្រីមាសទី៣ នេះ គម្រោងបានគាំទ្របន្ថែមដល់កិច្ចប្រជុំថ្នាក់តំបន់ចំនួនពីរគឺ នៅខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ។ ជាលទ្ធផលនៃកិច្ចប្រជុំ សមាជិកបានរៀនសូត្របន្ថែមអំពីតួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងប្រកាសអនុញ្ញាត ព្រមទាំងមានទទួលបានចំណេះដឹងថ្មីៗលើបច្ចេកវិទ្យាក្នុងវិស័យទឹកស្អាត លក្ខខណ្ឌនានាក្នុងការទទួលបានហិរញ្ញប្បទាន និងលក្ខខណ្ឌនានាដើម្បីចូលរួមសិក្សាផែនការមេដែលគាំទ្រដោយអង្គការ Water.org ផងដែរ។

### ៥.១.៤ កិច្ចសហការជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍

តបតាមការអញ្ជើញរបស់អង្គការ Water. org **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត និងបុគ្គលិកសមាគមចំនួន៣នាក់បានចូលរួម **«វេទិកាហិរញ្ញប្បទានសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម»** នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤ នៅសណ្ឋាគារ Fairmont Makati នៃទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន។ ក្នុងវេទិកានោះផងដែរ លោក **លឹម មិញ** នាយកប្រតិបត្តិសមាគមបានអញ្ជើញចូលរួមជាវាគ្មិនពិភាក្សាលើប្រធានបទស្តីពី **«ទិដ្ឋភាពទូទៅនៃការទទួលបានហិរញ្ញប្បទានសម្រាប់វិស័យទឹក និងអនាម័យ»** ក្នុងកិច្ចសន្ទនាជាអន្តរជាតិផងដែរ។




*រូបភាពទី១៧៖ វេទិកាហិរញ្ញប្បទានសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម*

### ៥.១.៥ ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

ក្រុមការងារគម្រោងបានសម្របសម្រួល និងតាមដានសមាជិកដែលទទួលបានប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ)FIs(។ ជាលទ្ធផលប្រតិបត្តិករចំនួន ២ស្ថានីយបានទទួលប្រាក់កម្ចីដើម្បីពង្រីកអាជីវកម្មចំនួនប្រមាណ **១០០០.០៥០.ដុល្លារ**

**អាមេរិក** ពីធនាគារ SME Bank និងមូលនិធិ Stone Family Foundation។ ទន្ទឹមនឹងនេះ ស្ថានីយចំនួន២ កំពុងសិក្សាកម្ចីពីធនាគារ SME Bank ផងដែរ។

ក្រៅពីនេះសមាគមក៏បានណែនាំប្រតិបត្តិករដែលមានតម្រូវការកម្ចីឱ្យទំនាក់ទំនងទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុដែលជាដៃគូរបស់សមាគម និងអង្គការ Water.org ផងដែរ។

### ៥.១.៦ វគ្គបណ្តុះបណ្តាលដល់ស្ថាប័នហិរញ្ញវត្ថុ

តាមរយៈការគាំទ្ររបស់អង្គការ Water.org នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាបានសហការជាមួយធនាគារ Phillip Bank រៀបចំវគ្គបណ្តុះបណ្តាលស្តីពី«ការណែនាំអំពីអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនៅប្រទេសកម្ពុជា» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួង ឧរបន ជាគណៈអធិបតី។ វគ្គបណ្តុះបណ្តាលនាពេលនេះ មានការចូលរួមពីថ្នាក់ដឹកនាំ និងប្រធានសាខានៃធនាគារ Phillip Bank តំណាងអង្គការ Water.org និងបុគ្គលិកសមាគម។

គោលបំណង៖ នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល សិក្ខាកាមអាច៖

១. ពិពណ៌នាអំពីទិដ្ឋភាពទូទៅនៃវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា
២. កំណត់អត្តសញ្ញាណរួមនៃដំណើរការអាជីវកម្មទឹកស្អាតឯកជន (ភាពខ្លាំង បញ្ហាប្រឈម និងឱកាស-តម្រូវការរបស់ប្រតិបត្តិករ)
៣. កំណត់ការវិនិយោគសំខាន់ៗក្នុងអាជីវកម្មទឹកស្អាត (ប្រភពទឹក រោងចក្រផលិតទឹកស្អាត ការចែកចាយប្រតិបត្តិការ (អគ្គិសនី ម៉ូទ័រ បុគ្គលិក សារធាតុគីមី)
៤. កំណត់ហានិភ័យ និងឱកាសក្នុងការវិនិយោគក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត។

### ៥.១.៧ ការចុះប្រមូលទិន្នន័យសិក្សាផែនការមេ

តាមរយៈគម្រោងមូលនិធិការគាំទ្រពីអង្គការ Water. org បុគ្គលិកជំនាញរបស់ក្រុមហ៊ុន iSEA សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងអង្គការ Water.Org បានចុះប្រមូលព័ត៌មាន និងសិក្សាលើហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថានីយដូចខាងក្រោម ដើម្បីរៀបចំផែនការមេ និងផែនការអភិវឌ្ឍន៍អាជីវកម្ម៖

១. ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ នៅស្ថានីយទឹកស្អាតសាលាលេខ ៥ ខេត្តកំពង់ឆ្នាំង
២. ថ្ងៃទី២២-២៣ ខែកក្កដា ឆ្នាំ២០២៤ នៅស្ថានីយទឹកស្អាតសូទ្រនិគម ខេត្តសៀមរាប
៣. ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ នៅស្ថានីយទឹកស្អាតកំពង់ចំលង ខេត្តកណ្តាល
៤. ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៤ នៅស្ថានីយទឹកស្អាត ចំការលើ ខេត្តកំពង់ចាម។

ក្នុងត្រីមាសទី៣ ក្រុមការងារបានរៀបចំសេចក្តីជូនដំណឹង ស្តីពីការប្រកាសជ្រើសរើសប្រតិបត្តិករជាសមាជិកសមាគមចំនួន ១២ស្ថានីយ ដើម្បីចូលរួមអនុវត្តគម្រោងថ្មីដែលមានឈ្មោះថា *«ការកែលម្អការគ្រប ដណ្តប់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ដើម្បីឱ្យប្រជាជនមានទឹកស្អាតប្រើប្រាស់»*។ ជាលទ្ធផល ក្រុមការងារទទួលបានអ្នកដាក់ពាក្យចំនួន ១៣ ស្ថានីយ។

យោងតាមកិច្ចប្រជុំរវាងក្រុមការងារសមាគម និងអង្គការ Water.org នោះ សមាគមគ្រោងនឹងជ្រើសរើសប្រតិបត្តិករបន្ថែមចំនួន ១២ស្ថានីយទៀត ដើម្បីអនុវត្តគម្រោងសម្រាប់ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៦។



*រូបភាពទី១៨៖ ការចុះប្រមូលព័ត៌មាន និងសិក្សាលើហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថានីយទឹកស្អាតកំពង់ចំលង*

### ៥.១.៨ កិច្ចសម្ភាសជាមួយប្រតិបត្តិករ និងគ្រួសារដែលបានប្រើប្រាស់ទឹកស្អាត

ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងអង្គការ Water. org បានចុះជួបប្រជុំជាមួយម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កណ្តឹង និងអតិថិជនចំនួន ៣គ្រួសារ របស់ស្ថានីយនេះ ដែលស្ថិតនៅឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ។ គោលបំណងនៃការជួបប្រជុំនេះ ដើម្បីស្វែងយល់អំពីការកែលម្អអាជីវកម្មរបស់ស្ថានីយ និងភាពពេញចិត្តរបស់អតិថិជនក្នុងការប្រើប្រាស់សេវាទឹកស្អាត។



*រូបភាពទី១៩៖ កិច្ចសម្ភាសជាមួយប្រតិបត្តិករ និងគ្រួសារដែលបានប្រើប្រាស់ទឹកស្អាត*

### ៥.១.៨ កិច្ចប្រជុំជាមួយក្រសួង ឧវបន

ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងអង្គការ Water.org បានជួបប្រជុំជាមួយមន្ត្រីអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីពិភាក្សាអំពីលទ្ធផលនៃការអនុវត្តគម្រោង និងផែនការចុះបង្វឹក លើបច្ចេកទេសផលិតទឹកស្អាត តាមស្ថានីយនីមួយៗរបស់ប្រតិបត្តិករក្នុងគម្រោង

ដែលគាំទ្រដោយអង្គការ Water.org។ សមាសភាពអ្នកចូលរួមសរុបមានចំនួន ៩នាក់ដែលអញ្ជើញពី (ស្ត្រី ៤នាក់) អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួង ឧវបន ចំនួន ២នាក់ តំណាងអង្គការ Water.org ចំនួន ២នាក់ និងបុគ្គលិកសមាគមចំនួន ៥នាក់។



*រូបភាពទី២០៖ ៖ កិច្ចប្រជុំជាមួយមន្ត្រីអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួង ឧវបន*

### ៥.១.៩ កិច្ចប្រជុំក្នុងគម្រោង

នៅក្នុងត្រីមាសទី៣ ក្រុមការងាររបស់គម្រោងបានរៀបចំកិច្ចប្រជុំដូចខាងក្រោម៖

១. ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ ជួបប្រជុំជាមួយក្រុមការងារសមាគម និងអង្គការ Water.org ដើម្បីពិភាក្សាឆ្លុះបញ្ចាំងអំពីការសិក្សាផែនការមេដែលបានអនុវត្តបាន ៣ស្ថានីយកន្លងមក ព្រមទាំងរៀបចំផែនការសម្រាប់ការសិក្សាសម្រាប់ស្ថានីយផ្សេងៗទៀត។

២. ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ ជួបប្រជុំជាមួយក្រុមការងារក្រុមហ៊ុន iSEA អង្គការ Water.org ដើម្បីពិភាក្សាឆ្លុះបញ្ចាំងអំពីការសិក្សាផែនការមេដែលបានអនុវត្តបាន ៤ស្ថានីយកន្លងមក ព្រមទាំងរៀបចំផែនការសម្រាប់ការសិក្សាសម្រាប់ស្ថានីយចំនួន២បន្ថែមទៀត។

២. ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ ជួបប្រជុំជាមួយក្រុមការងារក្រុមហ៊ុន iSEA និងអង្គការ Water.org ដើម្បីពិភាក្សាអំពីលទ្ធផលនៃការសិក្សាផែនការមេលើផ្នែកបច្ចេកទេស និងទម្រង់ផែនការអាជីវកម្ម។ លើសពីនេះទៀត ក្រុមការងារសមាគម និងអង្គការ Water.org បានពិភាក្សាអំពីគម្រោងថ្មីបន្តដែលនឹងត្រូវអនុវត្តនៅឆ្នាំ២០២៥ ដល់ឆ្នាំ២០២៦។



*រូបភាពទី២១៖ ៖ កិច្ចប្រជុំជាមួយក្រុមការងារក្រុមហ៊ុន iSEA និងអង្គការ Water.org*

## ៥.២. គម្រោង«សហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ន» (EMW)

ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ សមាគមបានជួបប្រជុំជាមួយអង្គការ EMW ដើម្បីពិភាក្សាពីការអនុវត្តគម្រោងកន្លងមក និងរួមគ្នាបង្កើតគម្រោងនៅពេលអនាគតដ៏ខ្លីខាងមុខដើម្បីឱ្យប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាត និងអនាម័យ តាមរយៈប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។

## ៥.៣ គម្រោង .«ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹក សម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា»

ក្នុងត្រីមាសទី៣នេះ បុគ្គលិកសមាគមបានធ្វើការតាមដានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន៣ ពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាស រួមមាន៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតពាម គាត់បានរៀបចំសំណាញ់ការពារក្បាលបូមទឹកឆៅរួចរាល់ និងបានចាក់បង្គោលរួចខ្លះក្នុងការដាក់ផ្លាកសញ្ញាដើម្បីការពារបំពង់ទឹកស្អាត និងវិធានការផ្សេងៗទៀតគាត់នឹងព្យាយាមធ្វើបន្ថែម។

២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្បែងខ្ពស់ បានលើកដីជាទំនប់ដើម្បីការពារវ៉ាំនដោះភក់ និងអាងស្តុកទឹក បានរួចរាល់ បានចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរជារៀងរាល់ខែ និងបានធ្វើបទបង្ហាញពីផលប៉ះពាល់ពីការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត ជាពិសេសអាជ្ញាធរបានផ្តល់ព័ត៌មានមុនពេលដែលគេចាំផ្តើមធ្វើផ្លូវ ឬក៏ជួលជុលផ្លូវ ដើម្បីកាត់បន្ថយការខូចខាតបណ្តាញបំពង់ទឹកស្អាត។

៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលង្វែក ធ្វើសំណាញ់ការពារក្បាលបូមទឹកឆៅរួចរាល់ ព្រមទាំងបានចូលរួមកិច្ចប្រជុំជាមួយខាងអាជ្ញាធរខ្លះ និងបានផ្សព្វផ្សាយពីផលប៉ះពាល់ពីការប្រើប្រាស់សារជាតុគីមី និងការចោលសំរាមចូលក្នុងប្រភពទឹក និងបានចាប់ផ្តើមកក្នុងការរៀបចំជាលិខិតជូនដំណឹងទៅមន្ទីរសាធារណៈការខេត្តកំពង់ឆ្នាំង អំពីការ ដាក់បណ្តាញបំពង់ទឹកស្អាត។

## ៥.៤. គម្រោង «ការជ្រើសរើសប្រតិបត្តិករឯកជនឆ្នើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត» (JICA)

សមាគមបានសហការជាមួយ ក្រសួង ឧរបន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តជាតិជប៉ុន )JICA) ក្នុងការអនុវត្តគម្រោងមួយដែលមានឈ្មោះថា **«ការជ្រើសរើសប្រតិបត្តិករឯកជនឆ្នើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត»**។ គោលបំណងសំខាន់នៃគម្រោងនេះ គឺការចងក្រងនូវនីតិវិធីនៃការអនុវត្តល្អបំផុត -ករណីសិក្សាជោគជ័យ )Success Story ) តាមលក្ខណៈវិនិច្ឆ័យដែលគម្រោងបានកំណត់ ដើម្បីឱ្យប្រតិបត្តិករផ្សេងៗទៀត អាចយកទៅប្រើប្រាស់ ឬអនុវត្តតាម។

ក្នុងត្រីមាសទី៣នេះ ក្រុមការងារបានជ្រើសរើសប្រតិបត្តិករចំនួន ១០ស្ថានីយ ដើម្បីសិក្សាលម្អិតលើលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឆ្នើមចំនួន ៥ស្ថានីយ។ ជាលទ្ធផលក្រុមការងារជ្រើសរើសបានប្រតិបត្តិករតាមក្រុមនីមួយៗ ដូចខាងក្រោម៖

- **ក្រុមទី១៖** ១ ប្រតិបត្តិករត្រូវបានជ្រើសរើស
- **ក្រុមទី២៖** ៤ ប្រតិបត្តិករត្រូវបានជ្រើសរើស
- **ក្រុមទី៣៖** ៥ ប្រតិបត្តិករត្រូវបានជ្រើសរើស

នៅក្នុងត្រីមាសបន្ទាប់ ក្រុមការងារនឹងចុះសិក្សាលម្អិតដល់ស្ថានីយសម្រាប់ប្រតិបត្តិករដែលបានជ្រើសរើសទាំង ១០ស្ថានីយ។